ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៤១ សហវ

## ប្រកាសអន្តរក្រសួង

ស្តីពី

## ការបង្កើតក្រុមដឹកនាំការងារបើកផ្តល់សាច់ប្រាក់ដល់កិច្ចអភិវឌ្ឍន៍វិស័យសង្គម

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធ ហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការ គ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០២

ៗ

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ២០០៣

-បានឃើញ អនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល

## សំរេច

**ប្រការ១:** បង្កើតក្រុមដឹកនាំការងារបើកផ្តល់សាច់ប្រាក់ដល់កិច្ចអភិវឌ្ឍន៍វិស័យសង្គម ដែលមានសមាជិកដូចរាយនាមខាងក្រោម:

| | | |
|---|---|---|
| ១. ឯកឧត្តម ជុំ គឹមឡេង | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម តែ គុយសៀង | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល | អនុប្រធាន |
| ៣. ឯកឧត្តម ឆយ អូន | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៤. លោក ខិន យន | ប្រធានរតនាគារជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៥. លោក នុច ឡេង | ប្រធាននាយកដ្ឋានថវិកា.និងហិរញ្ញកិច្ច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦. លោក ឆាយ ទុង | ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៧. លោក លី សន្តិ | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៨. លោក ជា គឹមឡុង | ប្រធាននាយកដ្ឋានថវិកានិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល | សមាជិក |

**ប្រការ២:** លេខាធិការដ្ឋានរបស់ក្រុមដឹកនាំការងារបើកផ្តល់សាច់ប្រាក់ដល់កិច្ចអភិវឌ្ឍន៍វិស័យសង្គម ត្រូវបានបង្កើត និងមានសមាជិកដូចខាងក្រោម:

| | | |
|---|---|---|
| ១. លោក ហ៊ីង សុវណ្ណ | អនុប្រធានទី១រតនាគារជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. លោក យ៉ិន ថាច | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៣. លោកស្រី យក់ សម្បត្តិ | អនុប្រធាននាយកដ្ឋានថវិកានិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល | អនុប្រធាន |
| ៤. លោក អៀង ស៊ុនលី | អនុប្រធានទី១នាយកដ្ឋានថវិកា.និងហិ.កិច្ច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៥. លោក ឈឹម សារ៉េត | អនុប្រធានរតនាគារជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦. លោក ទន្យ វិជ័រតុល | អនុប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៧. លោក ស៊ាន ម៉ាឡូត | ប្រធានអង្គភាពគ្រប់គ្រងរូបិយប័ណ្ណ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៨. លោក ជា មិន | ប្រធានការិយាល័យគ្រប់គ្រងការងារហិ.កិច្ច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៩. កញ្ញា ឃុត ដាវី | ប្រធានការិយាល័យផែនការ ក្រសួងសុខាភិបាល | សមាជិក |
| ១០. លោក លី សំអុល | ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងសុខាភិបាល | សមាជិក |
| ១១. លោក ឯក ចន្ថា | ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១២. លោក ខួន លក្ខណា | មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |

<u>ប្រការ៣</u>: ក្រុមដឹកនាំការងារបើកផ្តល់សាច់ប្រាក់ដល់កិច្ចអភិវឌ្ឍន៍វិស័យសង្គម ត្រូវទទួលបន្ទុក:

. កំណត់អោយបានអំពីមូលហេតុ ដែលនាំអោយការបើកផ្តល់សាច់ប្រាក់មានកំរិតទាបដល់កិច្ចអភិវឌ្ឍន៍វិស័យសង្គម ពិសេសវិស័យអប់រំ និងសុខាភិបាល ព្រមទាំងផ្តល់អនុសាសន៍ដើម្បីធ្វើសកម្មភាពកែសំរួល និងធ្វើអោយប្រសើរឡើង

. កំណត់អោយបាននូវការលំបាកនានារបស់ក្រសួងស្ថាប័ន ដែលអនុវត្តកម្មវិធីសកម្មភាពអាទិភាព និងលើកឡើងនូវវិធានការដោះស្រាយ

. រៀបចំផែនការសកម្មភាពរយៈពេលខ្លីស្តីពីការបង្កើនសន្ទុះនៃការបើកផ្តល់សាច់ប្រាក់ ដោយផ្អែកតាមការសំរេចចិត្តនៃគោលនយោបាយអភិវឌ្ឍន៍វិស័យសង្គម ។

<u>ប្រការ៤</u>: លេខាធិការដ្ឋានមានសិទ្ធិអញ្ជើញជំនាញការបរទេសពាក់ព័ន្ធចូលរួមតាមការចាំបាច់ និងមានភារកិច្ចរៀបចំលិខិតអញ្ជើញប្រជុំគ្រប់សមាជិក នៃក្រុមដឹកនាំការងារបើកផ្តល់សាច់ប្រាក់ដល់កិច្ចអភិវឌ្ឍន៍វិស័យសង្គម និងរៀបចំខ្លឹមសារ របៀបវារៈ កំណត់ហេតុ និងបញ្ជីវត្តមាននៃអង្គប្រជុំ (អាចធ្វើឡើងជាភាសាអង់គ្លេសផងដែរ) ជាពិសេសរបាយការណ៍សង្ខេប ស្តីពីស្ថានភាពបើកផ្តល់សាច់ប្រាក់ជូនក្រសួងស្ថាប័ននានា ដែលអនុវត្តកម្មវិធីសកម្មភាពអាទិភាព ជូនដៃគូអ្នកផ្តល់ជំនួយដែលពាក់ព័ន្ធនានា ។

<u>ប្រការ៥</u>: អគ្គលេខាធិការ អគ្គនាយក ខុទ្ទកាល័យ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និង ឯកឧត្តម អស់លោកដូចមានចែងក្នុងប្រការ១ និង ប្រការ២ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០០៣

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ
យុវជន និងកីឡា

អ៊ឹម_សិទ្ធី

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសុខាភិបាល

វេជ្ជ. ហុង_ស៊ុនហួត

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

<u>ចម្លងជូន</u>

. គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
. គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា
. គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងក្រសួងសុខាភិបាល
. ដូចប្រការ ១ និងប្រការ ២
. ឯកសារ និង កាលប្បវត្តិ